# អង្គការឃែរកម្ពុជា_ប៉ៃលិន

## ការដាំដុះដំណាំស្រូវ

## បច្ចេកទេសស្ទូងស្រូវជាជួរ





**គំរោងសមារណកម្មសកម្មភាពមីន**

**និងសុវត្ថិភាពស្បៀង   ខេត្តប៉ៃលិន**

Australian Government

AusAID

## ១. សេចក្តីផ្តើម

បច្ចេកទេសស្ទូងស្រូវ ជាជួរត្រូវបានផ្សព្វផ្សាយ ដើម្បីចូលរួមធ្វើឱ្យប្រសើរឡើងលើផ្នែកសន្តិ-សុខស្បៀង និងលើកស្ទួយកំរិតជីវភាពរបស់កសិករយើង ។ ការស្ទូងស្រូវជាជួរ គឺផ្តោតសំខាន់ លើការស្ទូងឱ្យ ត្រង់ជួររៀបចំដីស្រែឱ្យបានស្មើល្អ អាយុសំណាបសមស្រប និង មានការថែទាំបានល្អ ដោយពិនិត្យទៅលើស្មៅ ការគ្រប់គ្រងទឹកសារធាតុចិញ្ចឹម និងកត្តាចង្រៃនានា ។

### សារៈប្រយោជន៍នៃការស្ទូងស្រូវជាជួរ

- ទទួលបានទិន្នផលខ្ពស់ជាងការស្ទូងតាមទំលាប់កសិករ
- ផ្តល់លក្ខខណ្ឌសមស្រប ក្នុងការប្រើប្រាស់ពន្លឺ ខ្យល់ និងការស្រូបយកសារធាតុចិញ្ចឹមដើម្បីជំរុញការលូតលាស់របស់ដំណាំ
- មានភាពងាយស្រួលក្នុងការថែទាំ (បោចស្មៅ បាចជី ជាដើម)
- ប្រើប្រាស់ពូជតិចល្មមត្រឹមតែ ៤០-៦០ គ.ក/ហ.ត



### ការអនុវត្តន៍ដាំដុះដំណាំស្រូវក្រោមការគាំទ្រពីគម្រោង

- ៣៦២ គ្រួសារបានទទួលការគាំទ្រពីគម្រោងអង្គការយែរ
- កសិករលើសពី ៨០ ភាគរយ បានអនុវត្តការដាំដុះដំណាំស្រូវក្រោមការផ្គត់ផ្គង់ពីគម្រោង
- ទិន្នផលស្រូវមានការកើនឡើងប្រមាណ ៣២ ភាគរយ បើធៀបជាមួយនឹងការដាំដុះដំណាំស្រូវតាមទំលាប់កសិករ

## ២. ការរៀបចំថ្នាលសំណាប

- ភ្ជួរដី ២-៣ ដង លើថ្នាលសំណាប មុនពេលសាប
- រៀបចំដីថ្នាលសំណាបឱ្យម៉ត់ កៀរឱ្យស្មើល្អ និងមិនដក់ទឹក
- ហាលគ្រាប់ពូជ ១ថ្ងៃ ត្រាំទឹក ១២ ម៉ោង ផ្អាប់ ៤៨ ម៉ោង ២
- ទំហំថ្នាលសំណាប ១០ ម ប្រើពូជ ១ គ.ក
- សាបពូជ ៤០-៦០ គ.ក សំរាប់ស្ទូងលើផ្ទៃដីមួយហិកតា
- សាបស្តើងល្មម និងស្មើដៃដើម្បីទទួលបានសំណាបថ្លោសល្អ





## ៣. អាយុសំណាប


ពូជដុះល្អ អត្រាដំណុះខ្ពស់ សាបរង្វើល សំណាបដើមថ្លោស


ពូជដុះមិនល្អ អត្រាដំណុះទាប សាបញឹក

អាយុសំណាប គួរបែងចែកទៅតាមអាយុកាលរបស់ដំណាំស្រូវៈ

- ស្រូវស្រាលៈ អាយុសំណាបពី ២០ ទៅ ២៥ ថ្ងៃ
- ស្រូវកណ្តាល និងស្រូវធ្ងន់ៈ ២៥ ទៅ ៣០ ថ្ងៃ

## ៤. ការស្ទូងស្រូវ

- ស្ទូងជាជួរស្មើគ្នា
- ចន្លោះគុម្ព ២៥ ស.ម និងជួរ ២៥ ស.ម
- ស្ទូង ២ - ៣ ដើមក្នុង ១ គុម្ព និង ស្ទូងរាក់ៗ



## ៥. ការគ្រប់គ្រងទឹក

### តំរូវការកំពស់ទឹក

តំរូវការកំពស់ទឹកដណាំស្រូវមាន លក្ខណៈមិនដូចគ្នាទេគឺអាស្រ័យទៅលើដំណាក់កាលលូតលាស់របស់ដំណាំស្រូវ ។ ខាងក្រោមនេះ គឺជាអនុសាន៍មួយចំនួនសំរាប់ដំណាំស្រូវប្រសិនបើយើងមានលទ្ធភាពគ្រាប់គ្រាន់សំរាប់ការគ្រប់គ្រងទឹកៈ

| **ក- វគ្គលូតលាស់** | **តំរូវការទឹក** |
|---|---|
| ○ ដំណាក់កាលដុះពន្លក | សំនើមដី |
| ○ ដំណាក់កាលសំណាប | ០ - ២១ ស.ម |
| ○ ដំណាក់កាលជាសន្ទូង | ១០ - ១២ ស.ម |
| ○ ដំណាក់កាលបែកគុម្ព | ២ - ៥ ស.ម |
| ○ ដំណាក់កាលពន្លូតដើម | ៥ ស.ម |

**ខ- វគ្គបង្កើតផល (មានរយៈពេល ៣៥ ថ្ងៃ)**

| | |
|---|---|
| ○ ដំណាក់កាលពន្លកកួរ | ៥ សម |
| ○ ដំណាក់កាលចេញកួរ | ៥ សម |
| ○ ដំណាក់កាលចេញផ្កា | ៥ សម |

| **គ- វគ្គទុំ (មានរយៈពេល ៣០ ថ្ងៃ)** | **តំរូវការទឹក** |
|---|---|
| ○ ដំណាក់កាលដាក់ទឹកដោះ | ២-៣ សម |
| ○ ដំណាក់កាលដាក់ម្សៅ | ១-២ សម |
| ○ ដំណាក់កាលទុំពេញលេញ | បង្ហូរទឹកចេញ |

## ៦. ការគ្រប់គ្រងសារធាតុចិញ្ចឹម

ស្ទើរតែគ្រប់រុក្ខជាតិទាំងអស់ត្រូវការសារធាតុចិញ្ចឹម នៅក្នុងនោះ សារ

ធាតុចំនួន ១៦ ប្រភេទត្រូវបានចាត់ទុកថាមាន សារៈសំខាន់ណាស់ សំរាប់ដំណើរការ លូតលាស់របស់រុក្ខជាតិ ។ សារធាតុទាំងនេះ មានដូចជា កាបូន (C) អ៊ីដ្រូសែន (H) អុកស៊ីសែន ($O_2$) អាសូត (N) ប៉ូតាស្យូម(K) កាល់ស្យូម (Ca) ម៉ាញ៉េស្យូម(Mg) ផូស្វ័រ(P) ស្ពាន់ធ័រ (S) ក្លរ (Cl) ដែក (Fe) បូរ៉ុង (B) ម៉ង់កាណែស (Mn) សង្កសី (Zn) ទង់ដែង (Cu) និងម៉ូលីបដេណូម (Mo)។

ក្នុងចំណោមសារធាតុទាំងនេះ យើងនឹងសិក្សាតែសារធាតុចិញ្ចឹមសំខាន់ចំនួន ៣ ទេ គឺមានអាសូត (N) ផូស្វ័រ (P) ប៉ូតាស្យូម (K)។ ប្រភេទជីដែលកសិករប្រើប្រាស់ ជាទូទៅមាន ២ប្រភេទ គឺជីគីមី និង ជីធម្មជាតិ ។

## ៦.១ - ជីធម្មជាតិ

### ៦.១.១- ជីកំប៉ុស្ដិ៍

កំប៉ុស្ដិ៍ជាកាកសំណល់រុក្ខជាតិផ្សេងៗលាមកសត្វ កាកសំណល់ជុំវិញផ្ទះ ឬកាកសំណល់ ក្នុងទីក្រុង ជាដើម ដែលយើងយកមកលាយបញ្ចូលគ្នាតាមបច្ចេកទេសរួចទុកអោយរលួយផុយ ។

ជីកំប៉ុស្ដិ៍ផ្ដល់នូវគុណប្រយោជន៍ដូចខាងក្រោម:

- មានប្រតិកម្ម (ឆាប់រលាយក្នុងដី) រហ័សជាងពពួកជីស្រស់
- ជាជីដ៏ល្អដោយមានសមាសធាតុចិញ្ចឹមជាច្រើន
- ប្រើប្រាស់អស់លទ្ធភាពនូវសមាសធាតុសរីរាង្គ (លាមកសត្វ កាកសំណល់ ស្លឹករុក្ខជាតិ)ដែលមានស្រាប់
- ជួយបង្កើនសមត្ថភាពស្រូបយកទឹក និងសារធាតុចិញ្ចឹម
- កាត់បន្ថយនូវសត្វល្អិតចង្រៃ ដោយសារកំដៅក្នុងគំនរខ្ពស់
- កាត់បន្ថយការបាត់បង់អាហ្សូត (ជាតិអាសូតណា នៅក្នុងដី)។

#### ក. វត្ថុធាតុដើមសំរាប់ធ្វើជីកំប៉ុស្ដិ៍

- ធាតុស្ងួត ឬធាតុដែលសំបូរកាបូន ដូចជា: ចំបើង ស្មៅស្ងួត ស្លឹកឈើ អាចមិរណាជាដើម
- ធាតុសើម ឬពពួកសំបូរជាតិអាសូត ដូចជា: ស្លឹកឈើស្រស់(ស្លឹកពពួកដំណាំក្លូរ ឬពពួកសណ្តែក) អាចមិសត្វ កាកសំណល់ផ្ទះបាយជាដើម ។
- ដីអាចជាដីស្រទាប់លើ ឬដីដំបូក ឬដីកំប៉ុស្ត៍ចាស់

**ខ. របៀបធ្វើ**

ការលាយវត្ថុធាតុដើមសំរាប់ធ្វើកំប៉ុស្ត៍មាន ២ វិធីគឺ:

- លាយសារធាតុទាំងនោះជាស្រទាប់ៗ
- លាយចូលគ្នាទាំងអស់តែម្តង

ជាទូទៅការរៀបស្រទាប់ មានលក្ខណ:ប្រសើរជាងការលាយ ចូលគ្នាទាំងអស់ ។ការរៀបជាស្រទាប់មានភាពងាយស្រួលក្នុងការរក្សាតុល្យភាពរវាងសារធាតុស្ងួត ធាតុសើម និងដី ។

ការរៀបជាស្រទាប់គេនិយមអនុវត្តដូចខាងក្រោមនេះ

- ស្រទាប់ទី ១ ធាតុស្ងួត (៣ដង)
- ស្រទាប់ទី ២ ធាតុសើម (២ដង)
- ស្រទាប់ទី ៣ ដី (កន្លះ ទៅ១ដង)

យើងអនុវត្តការរៀបជាប្រទាប់ៗនេះរហូតដល់ គ្រុងឬរណ្តៅដីពេញ ។ បរិមាណសារធាតុសំខាន់ៗ ទាំង៣ នៅពេលយើងលាយបញ្ចូលគ្នា



ដី(ដីស្រទាប់លើលាយជាមួយផេះ រឹកំប៉ុស្ត៍)

ធាតុសើម (ពពួកសំបូរអាសូត N)

សារធាតុស្ងួត (ពពួកសំបូរកាបូន C)

### គ-ការធ្វើរោងសំរាប់សន្សំជីធម្មជាតិ

- ធ្វើរបាព័ទ្ធជុំវិញអោយបានបណ្តោយ ៣ ម៉ែត្រ ទទឹងពី ១,៥ ទៅ ២ ម៉ែត្រ និងកំពស់១ម៉ែត្រ របាត្រូវពាសដោយដីដំបូកលាយចំបើងជុំវិញ ក្នុងរបាត្រូវខ័ណ្ឌ ជាបីអោយបានស្មើគ្នា។
- ត្រូវធ្វើដំបូលប្រក់ពីលើដើម្បីការពារការបាត់បង់ជីអាសូតហើយ ការពារទឹកភ្លៀង និងកំដៅថ្ងៃផង
- ត្រូវដាក់លាមកសត្វ សំរាមកាកសំណល់ចំណីសត្វ កាកសំណល់ផ្ទះបាយ គល់ជញ្ជ្រាំង
- រហូតដល់ពេញនៅក្នុងប្រឡោះ ទីមួយនៃរោងជីនោះ
- ពេលពេញប្រឡោះទី១ ហើយត្រូវចូកជីពីប្រឡោះទី១ដាក់ទៅក្នុងប្រឡោះទី២ ដោយដាក់ពីស្រទាប់លើទៅក្រោម និងពីស្រទាប់ក្រោមឡើងមកលើវិញ
- ប្រឡោះទី១ ទំនេរត្រូវដាក់សំរាម និងលាមកសត្វឡើងវិញ
- ពេលពេញប្រឡោះទី១ ម្តងទៀត ត្រូវចូកជីពីប្រឡោះទី២ ដាក់ទៅប្រឡោះទី៣ ហើយត្រូវចូកជីពីប្រឡោះទី១ ដាក់ ទៅប្រឡោះទី២វិញ ដោយដាក់ពីស្រទាប់លើទៅក្រោមពីស្រទាប់ក្រោមឡើងមកលើវិញ ដូចលើកមុន
- ពេលពេញប្រឡោះទី១ម្តងទៀតប្រឡោះទី៣ អាចយកទៅ ប្រើប្រាស់បាន

- នៅពេលសន្សំជី ត្រូវស្រោចទឹកអោយមានសំនើមជានិច្ច
- ធ្វើរបៀបនេះដដែលៗ និងទទួលបានជីប្រើជារៀងរាល់ពេល




រូបភាពទី ១៨ រោងសំរាប់សន្សំជីធម្មជាតិ

### ឃ- ចំណុចដែលត្រូវចងចាំនៅពេលធ្វើ និងប្រើជីកំប៉ុស្តិ៍

ដើម្បីផលិតអោយបាន ជីកំប៉ុស្តិ៍ ដែលមានគុណភាពល្អត្រូវចងចាំនូវចំណុចមួយចំនួនដូចខាងក្រោម:

- ប្រើសារធាតុសរីរាង្គ អោយបានច្រើនប្រភេទ
- ត្រូវរក្សាអោយមានតុល្យភាពរវាងធាតុស្ងួត និងធាតុសើម ជៀសវាងកុំអោយធាតុស្ងួត ច្រើនពេក ឬសើមពេក
- គំនរជីកំប៉ុស្តិ៍ត្រូវធានាអោយមានខ្យល់ចូល ពីព្រោះវាបង្ក អោយមានសត្វល្អិតតូចៗ មាន ប្រយោជន៍ច្រើនដូចជា ជន្លេន ដង្កូវដូង ជាដើម ដែលមានតួនាទីសំខាន់ជយយអោយដីមានជីជាតិ និង ដំណាំលូតលាស់បានល្អ ដើម្បីជួយអោយមានខ្យល់ចេញចូលបានគេត្រូវឧស្សាហ៍ត្រឡប់ជី ។ គេត្រូវជៀសវាងការធ្វើជីនៅក្នុងរណ្តៅដែលមានទឹកដក់ជាប់ ជា ពិសេសរដូវវស្សា
- នៅរដូវរាំងស្ងួត ហើយធាតុផ្សំរបស់ជីសំបូរដោយសារធាតុ ស្ងួត

យើងត្រូវឧស្សាហ៍ ស្រោចទឹកលើជី បន្ថែមទៀត

- រណ្តៅរីគំនរជីកំប៉ុស្តិដែលរួចរាល់ហើយសំរាប់ប្រើមាន គុណភាពល្អគឺ មិនមានក្លិនស្អុយ មិនក្តៅ រលួយចូលគ្នាអស់ (ដោយមិនអាចអោយ យើងស្គាល់បានថាតើធាតុណាជាធាតុ អ្វី) ។ ប្រសិនបើវាមិនទាន់ កាច់អស់ទេ នៅពេលយើងយក ទៅប្រើវានឹងបញ្ចេញកំដៅដែលប៉ះ ពាល់ដល់ឬស និងការ លូតលាស់របស់ដំណាំ ។
- គេអាចយកជីកំប៉ុស្ដ៍ទៅត្រាំក្នុងទឹក ហើយយកទឹកជីនេះស្រោចបំប៉ន ដល់សំណាបអោយលូតលាស់បានល្អ ។

*ដើម្បីអោយសំណាបលូតលាស់បានល្អ និងងាយដកយកទៅស្ទូង គួរ យកជីកំប៉ុស្ដ៍ទៅរោយល្មើ ថាលសណាប ហើយរាស់ចូលក្នុងដីបន្តិចៗ ។ បន្ទាប់មក អាចធ្វើការសាបលើថ្នាលយកតែម្តង ។*

### ៦.១.២- ជីស្រស់

ជីស្រស់ ត្រូវបានកសិករមួយចំនួនអនុវត្តការប្រើប្រាស់នៅក្នុង ផលិតកម្មដំណាំស្រូវ តាំងពីយូរមកហើយ ។ ការប្រើប្រាស់ជីស្រស់គឺជាវិធី សាស្រ្តជួយកែប្រែគុណភាពដី នឹង បង្កើនទិន្នផលដល់ស្រូវរបស់យើង អោ យកើនមួយកំរិតថែមទៀត ។

ជីស្រស់ជាដំណាំសំរាប់ដាំដើម្បីផ្តល់ជាតិអាសូត(N)ដល់ដំណាំស្រូវ។ ក្រោយពីដាំពី ៤០-៥០ថ្ងៃ កសិករបានភ្ជួរលុបកប់ដំណាំជីស្រស់នោះទៅ ក្នុងដី គឺនៅដំណាក់កាលរៀបចំដីសំរាប់ដាំដំណាំស្រូវ ។

ដំណាំជីស្រស់ជាដំណាំប្រភេទទី២ ដែលដាំមុនរឺបន្ទាប់ពីដាំដំណាំស្រូវ រឺ ជួនកាលនៅពេលដីស្រែទំនេរពី ការដាំដំណាំផ្សេងៗ ។ ស្លឹកឈើស្រស់ ដែលបានពីដំណាំ រឺព្រៃគម្ពោតផ្សេងៗ ក៏គេអាចយកទៅភ្ជួរលុប ដើម្បីធ្វើ

ជាជីស្រស់បានដែរ ។ ជាទូទៅជីបៃតងស្រស់មាន:

- ប្រភេទដែលអាចដាំជាអាហាររបស់មនុស្ស: មានដូចជាសណ្តែកបារាំង សណ្តែកសៀង សណ្តែកបាយ ជាដើម ដែល គេច្រើនដាំយកផលធ្វើជាអាហាររបស់មនុស្ស ហើយនៅសល់កាកសំណល់ពីសរីរាង្គដំណាំនេះ គេយកវាទៅធ្វើជាជីស្រស់ដោយភ្ជួរលប់ទៅក្នុងដី ដើម្បីធ្វើស្រូវរដូវបន្ទាប់ ។
- រុក្ខជាតិដែលគេយកមកធ្វើជីស្រស់: កន្ទំថេត អង្កាញ់ ទន្រ្ទាងខែត្រ អង្គាសដីជាដើម ដោយគេយកមកចិញ្រ្ចាំ រួចបាចនៅក្នុងស្រែហើយទើបភ្ជួរលប់ធ្វើជាជីស្រស់។
- ពពួករុក្ខជាតិក្នុងទឹក: ពពួកស្មៅ កំប្លោក និងចក ក៏គេអាច យកមកធ្វើជាជីស្រស់ បានដែរដោយវាអាចផ្តល់ជាតិអាសូត បានយ៉ាងល្អសំរាប់ដំណាំស្រូវ ។

## **៦.២- ជីគីមី**

ជីគីមី ជាទូទៅ មានសមាសធាតុបីចូលរួមជាសំខាន់រួមមាន អាសូត (N) ផូស្វ័រ (P) និងប៉ូតាស្យូម (K) ។ ក្រៅពីនេះ នៅក្នុងជីគីមីខ្លះ អាចមានសមាសធាតុបន្ទាប់បន្សំ ផ្សេងៗទៀតដូចជា ដែក ស៊ុលផាត កាល់ស្យូម ជាដើម ។

ឧទាហរណ៍: ជីអ៊ុយរ៉េ (៤៦-០០-០០) ដេអាប៉េ(១៨-៤៦-០០) (១៦-២០-០០) (១៥-១៥-១៥)

### **៦.២.១- តួនាទីនៃធាតុសមាសអាសូត N ផូស្វ័រ P ប៉ូតាស្យូម K**

#### ក- ជីអាសូត

ជីអាសូតជាអាហារសំខាន់បំផុតរបស់ដំណាំស្រូវដែលមានតួនាទី

ដូចខាងក្រោមៈ

- ធ្វើអោយស្រូវដុះលូតលាស់បានល្អ
- ធ្វើអោយស្រូវបែកគុម្ពធំ
- ចូលរួមក្នុងការជំរុញប្រតិកម្មរស្មីសំយោគ
- ធ្វើអោយស្រូវដាក់គ្រាប់បានល្អ

**ខ- ជីផូស្វ័រ**

ផូស្វ័រមានតួនាទីដូចជា

- ធ្វើអោយឬសលូតលាស់ល្អ
- ធ្វើអោយស្រូវចេញផ្កា (ស្រុះល្អ)
- ធ្វើអោយស្រូវមានសមត្ថភាពបង្កើតស្រទាប់ជាលិកាខ្ចីៗ
- ដឹកជញ្ជូនថាមពលក្នុងដើមស្រូវ ។

**គ- ជីប៉ូតាស្យូម**

ប៉ូតាស្យូមមានតួនាទី

- ជួយសំរួលបញ្ហាទឹកនៅក្នុងសរីរាង្គស្រូវ
- ធ្វើអោយស្រូវធន់នឹងជំងឺ
- ធ្វើអោយស្រូវធន់នឹងការដួលដើម
- ធ្វើអោយស្រូវដាក់គ្រាប់ល្អ (បង្កើនទំហំ និងទំងន់គ្រាប់) ។

### ៦.២.២- ចំណុចដែលត្រូវគិតដើម្បីប្រើជីគីមីអោយមានប្រសិទ្ធិភាព

- ដី ៖ តើដីរបស់យើងជាប្រភេទដីអ្វី ?
- ពូជ ៖ តើយើងប្រើពូជអ្វី? (ពូជទំនើប ឬពូជប្រពៃណី)
- រដូវកាលដាំដុះ តើយើងធ្វើការដាំដុះនៅរដូវណា ? (រដូវប្រាំង ឬ រដូវវស្សា)

- ទឹក: ជាប្រភេទស្រែមានទឹក ឬស្រែដែលគ្មានប្រភពទឹក ?
- ស្មៅ: នៅមុនពេលបាចជីតើស្រែយើងមានស្មៅដែរឬទេ?
  ដំណាក់កាលលូតលាស់: តើស្រូវដល់ដំណាក់កាលណា?
- កំរិតប្រើប្រាស់ជី: អាស្រ័យទៅតាមក្រុមដីនីមួយៗ និង បទដ្ឋានកំណត់អោយប្រើប្រាស់ ។

ឧទាហរណ៍ ១ ក្រុមដីប្រទះឡាង កំរិតប្រើប្រាស់ជី $N_{60}$ $P_{30}$ $K_{30}$

បរិមាណប្រើក្នុងដី១ហិកតាគឺ:

- ជីអ៊ុយរ៉េ(Urea) = ១០៥ គីឡូក្រាម
- ជីដេអាប៉េ (DAP) = ៦៥ គីឡូក្រាម
- ជីប៉ូតាស្យូមក្លរួ (Kcl) = ៥០ គីឡូក្រាម



រូបភាពទី ១៩ក្រុមដីប្រទះឡាង

ឧទាហរណ៍ ២ ក្រុមដីបាកាន កំរិតប្រើប្រាស់ជី $N_{70}$ $P_{30}$ $K_{15}$

បរិមាណប្រើក្នុងដី១ហិកតាគឺ:

- ជីអ៊ុយរ៉េ (Urea) = ១២៧ គីឡូក្រាម
- ជីដេអាប៉េ (DAP) = ៦៥ គីឡូក្រាម
- ជីប៉ូតាស្យូមក្លរួ (Kcl) = ២៥ គីឡូក្រាម



រូបភាពទី ២០ ក្រុមដីបាកាន

ឧទាហរណ៍ ៣ ក្រុមដីក្បាលពោធិ កំរិតប្រើប្រាស់ជី $N_{120}$ $P_{34}$ $K_0$

បរិមាណប្រើក្នុងដី១ហិកតាគឺ:

- ជីអ៊ុយរ៉េ (Urea) = ២៣២ គីឡូក្រាម
- ដេអាប៉េ (DAP) = ៧៤ គីឡូក្រាម



រូបភាពទី ២១ ក្រុមដីក្បាលពោធិ

### ៦.២.៣ - ការប្រើប្រាស់ជី

ការប្រើប្រាស់ជីគីមី ត្រូវបានធ្វើការពិសោធន៍ និង ណែនាំដោយក្រុមអ្នកស្រាវជ្រាវពិសោធន៍លើ ផលិតកម្មដំណាំស្រូវទៅតាមតំបន់ ផលិតកម្មនិមួយៗ ។ ទោះជាយ៉ាងណាក៏ដោយការប្រើប្រាស់ជីធម្មជាតិ (ជីលាមកសត្វ ជីកំប៉ុស្ដិ៍ ជីស្រស់ ជាដើម) ជាមូលដ្ឋានគ្រឹះក្នុងការប្រើប្រាស់ជីគីមីអោយមានប្រសិទ្ធិភាពខ្ពស់។

**ក- បរិមាណជីប្រើប្រាស់សំរាប់ដំណាំស្រូវ**

ការប្រើប្រាស់ជីមានការប្រែប្រួលទៅតាមប្រភេទដី ជីជាតិដីដែលមានស្រាប់ ពេលវេលានៃការប្រើប្រាស់ ពូជ ទឹក និង កត្តាផ្សេងៗ ។ ដូចនេះការកំណត់អនុសាសន៍សំរាប់បរិមាណជី មានការលំបាក ។ សូមពិនិត្យលើបរិមាណជីប្រើប្រាស់ក្នុងឧទាហរណ៍ខាងលើ ។

**ខ- ពេលវេលាប្រើប្រាស់សំរាប់ស្រូវស្ទូង**

- ស្រូវស្រាល:

ការបាចជីត្រូវធ្វើឡើង ដោយចែកជា៤លើកគឺ:

- លើកទី១ ទ្រាប់បាតមុនពេលស្ទូង ជីធម្មជាតិ១០០% ដេអាប៉េ ១០០% ប៉ូតាស្យូមក្លរួ១០០% ។ ការបាចជី ទ្រាប់បាតត្រូវធ្វើឡើងអោយបានស្មើល្អក្រោយភ្ជួររួច មុនរាស់លើកចុងក្រោយ រួចរាស់ស្ទូងតែម្ដង។
- លើកទី២ បាចបំប៉នជីអ៊ុយរ៉េ៣០% ក្រោយស្ទូងបាន រយៈពេលពី

១៣ ទៅ១៥ថ្ងៃ

- លើកទី៣ បាចបំប៉នជីអ៊ុយរ៉េ៣០% ក្រោយស្ទូងបាន រយៈពេលពី ២១ ទៅ២៥ថ្ងៃ
- លើកទី៤ បាចបំប៉នជីអ៊ុយរ៉េ៤០% ចុងក្រោយនៅ ពេលស្រូវក កើតកួរ (ស្រូវស្រាល ការកកើតកួរ នៅ ពេលស្រូវមានអាយុ ៥០ ទៅ ៥៥ថ្ងៃ ចាប់ពីថ្ងៃសាប។






រូបភាពទី ២២ ពូជស្រូវ "អ៊ីអ៊ែ៦៦" និង ពូជស្រូវ "សែនពិដោរ" ជាពូជស្រូវស្រាល

- ស្រូវកណ្តាល និងធ្ងន់

ការបាចជីត្រូវធ្វើឡើង ដោយចែកជា ៣លើកគឺៈ

- លើកទី១ ទ្រាប់បាតមុនពេលស្ទូង ជីធម្មជាតិ១០០% ដេអាប៉េ ១០០% ប៉ូតាស្យូម ក្លរ ១០០% និងជីអ៊ុយរ៉េ ៣០% និង អនុវត្តដូច ពូជស្រូវស្រាលផងដែរ
- លើកទី២ បាចបំប៉នជីអ៊ុយរ៉េ៤០% ក្រោយស្ទូងបាន រយៈពេលពី ២៥ ទៅ៣០ថ្ងៃ
- លើកទី៣ បាចបំប៉នជីអ៊ុយរ៉េ៣០% ចុងក្រោយនៅ

ពេលស្រូវកកើតកួរ

**ចំណាំ:** ការប្រើប្រាស់ជី និងបរិមាណជីដែលត្រូវប្រើមួយភាគធំត្រូវ ផ្អែកលើស្ថានភាពជាក់ស្តែងនៅគ្រប់ដំណាក់កាលលូតលាស់ ។




រូបភាពទី ២៣ ពូជស្រូវ ខា ៥ " ប្រភេទស្រូវធ្ងន់" និង ពូជស្រូវ ខា ១" ប្រភេទស្រូវកណ្តាល"

## ៧.ការប្រមូលផល

- ការប្រមូលផលគួរចាប់ផ្តើមនៅពេលស្រូវទុំចាប់ពី ៨៥ % ឡើង
- ការប្រមូលផលគួរធ្វើឡើងនៅពេលស្រូវដើមស្រូវស្ងួតល្អ